# សេចក្តីថ្លែងការណ៍រួម

## អង្គការសង្គមស៊ីវិលសាទរដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការមិនសាងសង់ទំនប់វារីអគ្គិសនីនៅលើទន្លេមេគង្គ

ភ្នំពេញ៖ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២៣ - យើងខ្ញុំ អង្គការសង្គមស៊ីវិល ដែលធ្វើការលើវិស័យគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ចទឹក និងការប្រែប្រួលអាកាសធាតុ សូមចូលរួមអបអរសាទរចំពោះក្រសួងបរិស្ថាន ដែលប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ខ្លួនចំពោះការមិនសាងសង់ទំនប់វារីអគ្គិសនីនៅលើទន្លេមេគង្គ នៅឯកិច្ចប្រជុំ COP លើកទី២៨ ដែលបានប្រារព្ធធ្វើនៅទីក្រុងឌូបៃ ប្រទេសអារ៉ាប់រួម ចាប់ពីថ្ងៃទី៣០ វិច្ឆិកា- ១៣ ធ្នូ ២០២៣។

ការបញ្ជាក់ជាថ្មីរបស់រាជរដ្ឋាភិបាលចំពោះការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការមិនសាងសង់ទំនប់វារីអគ្គិសនីនៅលើទន្លេមេគង្គ គឺជាការវិវត្តជាវិជ្ជមានដែលនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយកង្វល់ដែលកំពុងកើនឡើងចំពោះការប្រែប្រួលជាអវិជ្ជមានតាមដងទន្លេមេគង្គនាពេលបច្ចុប្បន្ន និងនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី។ ទន្លេមេគង្គបានស្ថិតក្នុងស្ថានភាពគួរឱ្យព្រួយបារម្ភចាប់តាំងពីឆ្នាំ២០១៩ ដោយសារស្ថានភាពរំហូរទឹកទាបដែលបង្កជាផលវិបាកធ្ងន់ធ្ងរ។ គណៈកម្មការទន្លេមេគង្គ (MRC) បានកត់ត្រាស្ថានភាពរំហូរទឹកទាបក្នុងរដូវវស្សាឆ្នាំ ២០១៩-២០២១ គឺជាកំណត់ត្រាទាបបំផុតក្នុងប្រវត្តិសាស្ត្រ[1]។ ស្ថានភាពដែលស្ថិតក្នុងកម្រិតប្រកាសអាសន្ននេះ បានបណ្តាលឱ្យទិន្នផលត្រី និងទិន្នផលស្រូវធ្លាក់ចុះ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាជនរាប់លាននាក់ដែលពឹងផ្អែកលើធនធានពីទន្លេ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានរាយការណ៍ពីការធ្លាក់ចុះនៃចំនួនត្រីទឹកសាបសរុបក្នុងចំនួនប្រហែល ១០.៥០% ក្នុងឆ្នាំ ២០១៩ និង ២២% ក្នុងឆ្នាំ ២០២០ បើប្រៀបធៀបទៅនឹងទិន្នន័យមូលដ្ឋានក្នុងឆ្នាំ ២០១៨[2] ។ ឥទ្ធិពលនេះបានបន្តរហូតមកដល់បច្ចុប្បន្ន ដោយសារស្ថានភាពរំហូរទឹកទាប។

---

[1] MRC (June 2021) Situation Report: Dry season hydrological conditions in the Lower Mekong River Basin.
[2] NGOF (2021) Final report: Assessing Low Water Flow's Impact on the Mekong Riverine and Tonle Sap Communities.

សហគមន៍មូលដ្ឋានក្នុងខេត្តស្ទឹងត្រែង បានឃើញពីការប្រែប្រួលរបបទឹកហូររបស់ទន្លេមេគង្គនាពេលថ្មីៗនេះ។ ស្ថិតនៅចម្ងាយប្រហែល៥គីឡូម៉ែត្រ ខាងក្រោមទំនប់វារីអគ្គិសនីដនសាហុង ភូមិក្រោម ក្នុងឃុំព្រះរំកិល ស្រុកបូរីអូស្វាយសែនជ័យ គឺធ្លាប់ជាតំបន់ទេសចរណ៍ធម្មជាតិដ៏ទាក់ទាញមួយ ដែលត្រូវបានគេស្គាល់ជាទូទៅដោយសារទេសភាពព្រៃលិចទឹកដ៏ស្រស់ស្អាត។ ក៏ប៉ុន្តែរយៈពេលប៉ុន្មានឆ្នាំចុងក្រោយមកនេះ ព្រៃលិចទឹកបានជួបប្រទះនូវការបាត់បង់ និងដួលរលំ។ តាមការប៉ាន់ស្មានដោយសហគមន៍មូលដ្ឋានប្រហែល៥០%នៃព្រៃលិចទឹកក្នុងភូមិក្រោមបានងាប់ និងដួលរលំ។ ថ្វីបើអត្តសញ្ញាណនៃប្រតិបត្តិការទំនប់វារីអគ្គិសនីនៅខាងលើត្រូវបានកំណត់ជាក្តីកង្វល់ដ៏ចំបងក៏ដោយ ក៏គ្មានការស៊ើបអង្កេតណាមួយត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហានេះដែរ។ ការរកឃើញរបស់សហគមន៍តាមរយៈ «ការតាមដានផលចាប់ត្រីដោយសហគមន៍» បានរកឃើញពីការថយចុះគួរឱ្យកត់សម្គាល់ប្រហែល ៨០% នៃការចាប់ត្រីជាលក្ខណៈគ្រួសារ។

កម្លាំងទឹកជំនន់នៅរដូវវស្សានៃទន្លេមេគង្គ ដើរតួយ៉ាងសំខាន់ធ្វើឱ្យមានរំហូរបញ្ច្រាសចូលទៅក្នុងបឹងទន្លេសាបតាមរយៈទន្លេសាប។ ក៏ប៉ុន្តែរំហូរទឹកទាបពីទន្លេមេគង្គក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បានធ្វើឱ្យបឹងទន្លេសាបស្ថិតក្នុងស្ថានភាពគួរឱ្យព្រួយបារម្ភ។ បើយោងទៅលើរបាយការណ៍របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ( NGO Forum ) រំហូរបញ្ច្រាសរបស់បឹងទន្លេសាបបានថយចុះជាបណ្តើរៗ គិតជាមធ្យមក្នុងរយៈពេលដប់ឆ្នាំចុងក្រោយ[3]នេះ ដែលបណ្តាលឱ្យកម្រិតទឹកបឹងទន្លេសាបមានកម្រិតទាប ប៉ះពាល់ដល់តំបន់លិចទឹក និងជម្រកត្រី។ របាយការណ៍ក៏បានអះអាងផងដែរថា បរិមាណទឹកបឹងទន្លេសាបចាប់ពីដើមឆ្នាំ២០២៣ ដល់ខែកញ្ញា ឆ្នាំ២០២៣ បានកាត់បន្ថយចំនួន៥០% បើធៀបនឹងកម្រិតមធ្យមរយៈពេលវែងក្នុងអំឡុងពេលដូចគ្នា។ របាយការណ៍ក៏បានព្យាករណ៍ថា កម្ពស់ទឹកបឹងទន្លេសាបនឹងមានទំនោរថយចុះ។

[3] NGOF (2023) Impacts of a low flow of water from the Mekong River to Tonle Sap Lake on the livelihoods of different communities and natural environments.

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គឺពិតជាបានឆ្លើយតបទៅនឹងការប្រែប្រួលដែលមិនធ្លាប់មានពីមុនមករបស់ទន្លេមេគង្គក្នុងរយៈពេលថ្មីៗនេះ និងរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់ដល់សហគមន៍នៅតាមដងទន្លេ។ យើងខ្ញុំ សូមសំដែងនូវការត្រេកអរយ៉ាងក្រៃលែងចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានប្រែក្លាយការប្តេជ្ញាចិត្តនេះឱ្យទៅជាឯកសារគោលនយោបាយ និងការអនុវត្តផែនការអភិវឌ្ឍន៍ថាមពលរបស់ជាតិ។ ការបង្វែរឆ្ពោះទៅរកជម្រើសថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលដែលកំពុងកើនឡើងក្នុងប្រទេស ក៏ដូចជាការអះអាងជាថ្មីក្នុងការចាកចេញពីការផលិតថាមពលពីធ្យូងថ្ម គឺជាការបង្ហាញអំពីការបន្សុីរបស់ប្រទេសកម្ពុជាជាមួយសហគមន៍អន្តរជាតិដើម្បីដោះស្រាយភាពអាសន្នអាកាសធាតុ។

ជាថ្មីម្តងទៀត យើងខ្ញុំដែលជាអង្គការសង្គមសុីវិលនៅកម្ពុជា សូមសំដែងនូវការគាំទ្រដោយក្តីរីករាយចំពោះរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការប្តេជ្ញាចិត្តដ៏រឹងមាំនេះ។ យើងខ្ញុំស្នើសុំដល់ក្រសួងពាក់ព័ន្ធទាំងឡាយ ឱ្យប្រកាន់ខ្ជាប់នូវការអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួន។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង**
លោក ម៉ក់ ប៊ុនធឿន ប្រធានកម្មវិធី
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
ទូរស័ព្ទ (៨៥៥ )១២ ៣៩៦ ០៥០
អ៊ីម៉ែល bunthoeurn@ngoforum.org.kh

## បញ្ជីឈ្មោះអង្គការមិនមែនរដ្ឋាភិបាលគាំទ្រសេចក្តីថ្លែងការណ៍

1. អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ ( AFD )
2. សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)
3. អង្គការចិត្តធម៌
4. សម្ព័ន្ធប្រជានេសាទកម្ពុជា (CCF)
5. សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
6. អង្គការសកម្មភាពដើម្បីសុខុមាលភាពស្រ្តីកម្ពុជា ( KWWA )
7. មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC)
8. អង្គការភូមិខ្ញុំ (MVi)
9. អង្គការអភិវឌ្ឍជនបទភូមិភាគឦសាន (NRD)
10. អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (NAS)
11. វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF)
12. អង្គការអុកស្វាមប្រចាំកម្ពុជា
13. អង្គការជំនួយជនបទ ( RAO )
14. អង្គការសហគមន៍អភិឌ្ឍន៍មិត្តជនបទ ( RFCD )
15. បណ្តាញអ្នកថែរក្សាទឹកបឹងទន្លេសាប ( TSW )
16. សមាគមសំឡេងស្ត្រីសហគមន៍ ( WCV )
17. អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក និងសេកុង (3SPN)